00223998

D99/3/6

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| សំណុំរឿងលេខ: | ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ០២) |
| ដាក់ទៅ: | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់: | ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ |
| ភាគីអ្នកដាក់: | សហមេធាវីរបស់លោក អៀង សារី |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 15 / 09 / 2008
ម៉ោង (Time/Heure): 11 : 05
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សំណើជាបន្ទាន់របស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីអំពី ការអនុវត្តន៍នូវ ការទទួលខុសត្រូវជាក្រុម សហឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច"**

---

**អ្នកដាក់ឯកសារ៖**
**សហមេធាវីរបស់លោក អៀង សារី**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

**អ្នកទទួលឯកសារ៖**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម ន័យ ថុល
ចៅក្រម ហួត វុទ្ធី
ចៅក្រម Katinka LAHUIS
ចៅក្រម Rowan DOWNING

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Robert PETIT

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 15 / Sept / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

2. ភាពស្មុគស្មាញនៃបញ្ហាទាំងឡាយដែលទាក់ទងនឹងបណ្តឹងឧទ្ធរណ៍នេះ ធ្វើអោយកិច្ចអន្តរាគមន៍របស់ លោក **អៀង សារី** ផ្តល់ភាពងាយស្រួលដល់ អង្គបុរេជំនុំជម្រះ ។ សារៈសំខាន់ជាងនេះទៅទៀត កិច្ចអន្តរាគមន៍នេះក៏នឹងថ្លែងប្រាស្រ័យផងដែរនូវការបំពាននូវគោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តីគ្នា បង្កឡើងដោយការដកហូតពី លោក **អៀង សារី** នូវសមភាពខាងនីតិវិធីដូចគ្នានឹង ក.ស.ព ។

3. វាជាផលប្រយោជន៍ខាងសេដ្ឋកិច្ចរបស់តុលាការ ដែលលោក **អៀង សារី** ត្រូវបានអនុញ្ញាតអោយធ្វើនូវសេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍នេះ នៅពេលដែលដំណោះស្រាយអំពីបញ្ហានេះនៅដំណាក់កាលនេះនឹងមានផលប៉ះពាល់យ៉ាងធំធេងដល់រយៈពេល ការចំណាយ និង វិសាលភាពនៃការស៊ើបសួរ តតាំងនឹងនឹងលោក **អៀង សារី** ។

4. ដោយសារមូលហេតុនៃភាពស្មុគស្មាញ និងសារៈសំខាន់នៃបញ្ហាថាតើ ការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួម អាចអនុវត្តបាននៅ អ.វ.ត.ក នោះ សវនាការដេញដោលផ្ទាល់មាត់នឹងត្រូវអនុញ្ញាត។ វាជាអត្ថប្រយោជន៍នៃយុត្តិធម៌ ដែលបញ្ហានេះនឹងត្រូវបានគេពិនិត្យយ៉ាងល្អិតល្អន់តាមរបៀបតម្លាភាព យុត្តិធម៌ និងដោយពេញលេញបរិបូរណ៍។

## II. ច្បាប់

5. ក្របខណ្ឌដែលអាចអនុវត្តបានសំរាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មានចែងនៅក្នុងវិធានផ្ទៃក្នុង ៧៤ ។ តា មវិធានផ្ទៃក្នុង ៧៤(២) "សហព្រះរាជអាជ្ញាអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីការបស់សហចៅក្រមស៊ើបអង្កេត"។ ផ្ទុយមកវិញ មេធាវីការពារក្តី មិនមានសិទ្ធិប្តឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយឡើយ[4]។

6. តាមវិធានផ្ទៃក្នុង ៧៥(៣) "ការដាក់សារណាបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ ទៅក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃគិតពីថ្ងៃបានទទួល

---

[4] សូមមើល វិធានផ្ទៃក្នុង ៧៤(៣) ដែលមានរាយនាមនូវប្រភេទជាក់លាក់នៃដីកាដែលមេធាវីការពារក្តីអាចប្តឹងឧទ្ធរណ៍ជំទាស់បាន។

00224000





លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី" ឬ "មេធាវីការពារ") តទៅនេះ សូមដាក់ជូននូវសំណើសុំដាក់សេចក្តីសន្និដ្ឋានស្តីអំពី ការអនុវត្តន៍នូវការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋ-កម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ឬ "ដីកាដំណោះស្រាយ") លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ៨ សីហា ២០០៨[1] ("បណ្តឹងឧទ្ធរណ៍របស់ ក.ស.ព")។ លោក **អៀង សារី** សូមស្នើដោយក្តីគោរពដាក់នូវសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរត្រឹមកំរិតទិដ្ឋភាពអង្គច្បាប់នៃទឡ្ហីករណ៍ទីពីរនៃ បណ្តឹងឧទ្ធរណ៍របស់ ក.ស.ព ដែលមាននាមជា កំហុសឆ្គងផ្នែកច្បាប់ដែលអះអាងដោយ ក.ស.ព នៅពេលដែលមានការខកខានមិនបានចេញដីកាបញ្ជូន **ឌុច** ទៅជំនុំជម្រះ ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម តាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ("JCE") [2]។ បើសិនជាសំណើសុំនេះនឹងត្រូវបានអនុញ្ញាតនោះ សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់លោក **អៀង សារី** *នឹងមិន*ផ្តល់ប្រាស្រ័យនូវបញ្ហាផ្សេងដូចជា ថាតើអង្គហេតុដែលរកឃើញដោយ សហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") នៅក្នុងដីកាដំណោះស្រាយអាចនឹងគាំទ្រនូវការប្រើប្រាស់នូវការទទួលខុសត្រូវជាទម្រង់ សហឧក្រិដ្ឋរួម ដែរឬទេ នៅក្នុងករណីនេះឡើយ[3]។

## I. សង្ខេបនូវទឡ្ហីករណ៍

1. ការអនុវត្តន៍នូវការទទួលខុសត្រូវជាទម្រង់ សហឧក្រិដ្ឋកម្មរួម នៅ អ.វ.ត.ក មានផលប៉ះពាល់ជាចំបងដល់ លោក **អៀង សារី** ដោយសារ លោក **អៀង សារី** ត្រូវបានចោទប្រកាន់ថាជាចំណែកមួយនៃដូចគ្នាក្នុង "ផែនការឧក្រិដ្ឋកម្មរួម" ដូច **ឌុច** ដែរ ។ ចិតក្នុងកាលៈទេសៈនេះ លោក **អៀង សារី** មានផលប្រយោជន៍ជាក់ស្តែងនៅក្នុងលទ្ធផលនៃបណ្តឹងឧទ្ធរណ៍នេះ និងត្រូវតែបានគេអនុញ្ញាតអោយដាក់ជូននូវសេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍នេះ។

---

1 ត្រូវបានដាក់ប្តឹងនូវថ្ងៃទី ៥ កញ្ញា ២០០៨

2 បណ្តឹងឧទ្ធរណ៍របស់ ក.ស.ព កថាខណ្ឌ ២(ii) កថាខណ្ឌ ៤៣-៥៨

3 កិច្ចការបែបនេះទំនងជាចេតនានៃបណ្តឹងឧទ្ធរណ៍របស់ ក.ស.ព ដែលតាមរយៈនេះ អង្គបុរេជំនុំជម្រះ ("អ.ប.ជ") ត្រូវបានស្នើសុំអោយវាយតំលៃឡើងវិញនូវភស្តុតាងដែលត្រួតពិនិត្យដោយ ក.ស.ច.ស ដើម្បីធ្វើអោយជាក់ច្បាស់ថាតើ វាបានធ្វើការវាយតម្លៃខាងអង្គហេតុដូចគ្នានឹង ក.ស.ច.ស ដែរឬទេ។ ការណ៍នេះទំនងជាហួសពីវិសាលភាពនៃបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ខណៈដែលវានឹងតម្រូវអោយមានការពិនិត្យឡើងវិញស្ទើរតែទាំងស្រុងតាមរយៈបណ្តឹងឧទ្ធរណ៍លើអង្គសេចក្តីសូម្បីតែនៅមុនពេលដែលការជំនុំជម្រះលើអង្គសេចក្តីត្រូវបានចាប់ផ្តើមទៅទៀត ។ ប៉ុន្តែ ការធ្វើវិសោធនកម្មទៅលើវិធានផ្ទៃក្នុង ១០៤ ដែលកំរិតយ៉ាងតឹងតែងដល់វិសាលភាពនៃបណ្តឹងឧទ្ធរណ៍លើសាលក្រមអង្គសេចក្តីទាំងមូល បង្កប់ន័យថា ទឡ្ហីករណ៍របស់ ក.ស.ព គឺហួសព្រំដែននៃវិសាលភាពនៃបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ។

សេចក្តីជូនដំណឹង អំពីសេចក្តីសម្រេច ឬ ដីកា"។ ការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះត្រូវតែដាក់ពាក្យក្នុងអំឡុងពេល "១៥ ថ្ងៃនៃប្រតិទិន គិតពីថ្ងៃជូនដំណឹងជាភាសាដែលភាគីបានស្នើសុំ ដែលបានចែងក្នុងមាត្រា ២.២ អំពីឯកសារដែលអ្នកទាំងនោះត្រូវឆ្លើយ តប"[5]។ នៅក្នុងករណី បណ្តឹងឧទ្ធរណ៍របស់ ក.ស.ព ត្រូវបានដាក់ និងជូនដំណឹងដល់គូភាគីកាលពីថ្ងៃ ៥ កញ្ញា ២០០៨។

7. សេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ដោយគូភាគីដទៃទៀត ឬសូម្បីតែតួអង្គខាងក្រៅ ដែលមានទំនាក់ទំនងមានកំរិតនឹងនីតិវិធី ត្រូវបានអនុញ្ញាតដោយអង្គបុរេជំនុំជម្រះ។ ជាឧទាហរណ៍ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់លោក **អៀង សារី** ជំទាស់នឹងដីកាឃុំខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះបានអញ្ជើញ ភាគីរដ្ឋប្បវេណីអោយដាក់អំណះអំណាងរបស់ខ្លួនដែរ[6]។ ជាងនេះទៅទៀត នៅក្នុងបណ្តឹងដដែលនេះ អង្គបុរេជំនុំជម្រះ បានចេញសេចក្តីជូនដំណឹងជាសាធារណៈអញ្ជើញ *អ្នកជូនយោបល់ដល់តុលាការ (amicus curiae)* អោយដាក់សារណា[7]ដែរ ដែ លការអញ្ជើញត្រូវបានទទួលដោយអ្នកឆ្លើយតបពីរនាក់[8]។ ការអនុវត្តនេះ ក៏ត្រូវបានយកតាមផងដែរនៅក្នុងបណ្តឹងឧទ្ធរណ៍ដទៃទៀតនៅចំពោះមុខអង្គបុរេជំនុំជម្រះ[9]។ បន្ទាប់ពីសវនាការដេញដោលដោយផ្ទាល់មាត់

---

5 មាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ អ.វ.ត.ក ០១/២០០៧/វ០២

6 *ករណី លោក អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០៣) ដីកាណែនាំអោយដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណាជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី ៣០ មេសា ២០០៨ ។

7 *ករណី លោក អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០៣) សេចក្តីជូនដំណឹង ចុះថ្ងៃទី ៤ កុម្ភៈ ២០០៨។

8 *ករណី លោក អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០៣) សារណារបស់ អ៊ែន ហាញឧុល ទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងនាមការបញ្ចេញយោបល់ផ្ទាល់ខ្លួន ចុះថ្ងៃទី ១៨ កុម្ភៈ ២០០៨ ។ *ករណី លោក អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០៣) សារណារបស់អ្នកជូនយោបល់ដល់តុលាការ (amicus curiae) ទាក់ទងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី ១៤ វិច្ឆិកា ២០០៧ ដាក់នៅថ្ងៃទី ១៩ កុម្ភៈ ២០០៨ ដោយលោក Mahdev Mohan និងលោកស្រី Vanita Ramani Mohan ។

9 ករណី កាំង ហ្គេចអ៊ាវ ("ឌុច") សំណុំរឿងលេខ ០៧-០៩-០០១ អវតក/អបជ សេចក្តីជូនដំណឹង ចុះថ្ងៃទី ៤ កញ្ញា ២០០៧ អញ្ជើញ "អង្គការ និងសាធារណៈជន" ថា ពួកគេអាចដាក់សារណានៃអ្នកជូនយោបល់ដល់តុលាការ (amicus curiae) ជាលាយលក្ខណ៍អក្សរ "ពាក់ព័ន្ធនឹងបញ្ហាណាមួយ"នៃបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ដែលដាក់ដោយមេធាវីការពាក្តីរបស់ ឌុច ។ *សូមមើលផងដែរ ករណី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០១) សេចក្តីជូនដំណឹង ចុះថ្ងៃទី ២៧ វិច្ឆិកា ២០០៧ និង *ករណី អៀង ធីរិទ្ធ* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០២) សេចក្តីជូនដំណឹង ចុះថ្ងៃទី ១៦ មករា ២០០៧ ។

លើបណ្ដឹងឧទ្ធរណ៍ ជំទាស់នឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន អង្គបុរេជំនុំជម្រះ ក៏បានអញ្ជើញអោយមានការឆ្លើយតបពីដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០១ ទៅនឹងពាក្យសុំអោយមានការពិចារណាសារជាថ្មីដែលដាក់ដោយភាគីរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ [10]។ ការណ៍នេះត្រូវបានអនុញ្ញាតដើម្បី "ជាប្រយោជន៍យុត្តិធម៌" [11]។

## III. ទឡ្ហីករណ៍

### ក. បញ្ហានៃការអនុវត្តការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួមមានផលប៉ះពាល់ជាចម្បងដល់លោក អៀង សារី

8. លោក **អៀង សារី** និង **ឌុច** ត្រូវបានចោទប្រកាន់ដោយ ក.ស.ព ថាជាចំណែកមួយនៃសហឧក្រិដ្ឋកម្មរួមតែមួយ[12]។ សេចក្ដីសំរេចក្រោយមកទៀតដោយ ក.ស.ច.ស ដែលបំបែកការស៊ើបសួរប្រឆាំងនឹង **ឌុច** ពីជនត្រូវចោទដទៃផ្សេងគ្នា[13] មើលទៅទំនងជាមិនមានឥទ្ធិពលអ្វីទេះទ្រឹស្ដីនៃរឿងក្ដីរបស់ ក.ស.ព វិលវល់ជុំវិញនឹងការអនុវត្តការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួម។ លោក **អៀង សារី** និង ជនត្រូវចោទបីរូបដទៃទៀតនៅតែកំពុងត្រូវបានគេស៊ើបសួរចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅមន្ទីរ ស-២១ ។ អាស្រ័យហេតុនេះ ការស៊ើបសួរប្រឆាំងនឹង **ឌុច** និង លោក **អៀង សារី** គឺមានជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធមិនអាចបេះចេញពីគ្នាបាន ។ ការណ៍នេះត្រូវបានទទួលស្គាល់ដោយ ក.ស.ព ដែលបានសារភាពថា **ឌុច** គឺ "នៅក្នុងរឿង

---

[10] *ករណី លោក អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០៣) សេចក្ដីណែនាំបន្ថែមទាក់ទងនឹងពាក្យសុំអោយពិចារណាឡើងវិញអំពីសិទ្ធិរបស់ដើមរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៧ កក្កដា ២០០៨ ។

[11] *ដូចគ្នា* ខាងលើ កថាខណ្ឌ ៣ ។

[12] *សូមមើល* សេចក្ដីប្រកាសព័ត៌មាន សេចក្ដីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា (១៨ កក្កដា ២០០៧) *អាចរកបាននៅគេហទំព័រនេះ៖* http://www.eccc.gov.kh/english/cabinet/press/33/Statement_of_Co-Prosecutors_18-July-2007_.pdf.

[13] *សូមមើល* ព័ត៌មានថ្មីៗដោយសហចៅក្រមស៊ើបអង្កេត ១ វិច្ឆិកា ២០០៧ ដែលសាធារណៈជនត្រូវជូនដំណឹងថា "នៅថ្ងៃទី ១៩កញ្ញា២០០៧[ក.ស.ច.ស]ដើម្បីធានានូវការគ្រប់គ្រងវិស័យយុត្តិធម៌ល្អបានសំរេចបង្គាប់អោយបំបែកសំណុំរឿង ឌុច ចេញ"

ក្តីទីទៃពីគ្នាមែន ប៉ុន្តែ [គឺ] [...] ជាចុងចោទតែមួយ[14]" ជាមួយលោក **អៀង សារី** ។ បើសិនជាការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួម បានត្រូវគេប្រើប្រាស់ប្រឆាំងនឹង ឌុច ដូច្នេះ ការអនុវត្តការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួមប្រឆាំងនឹង លោក **អៀង សារី** នឹងប្រែក្លាយជារឿងដែលស្ទើរតែមិនអាចជៀសវាងបាន។

9. ថ្មីៗនេះ មេធាវីការពារក្តីបានដាក់ពាក្យសុំទៅចំពោះមុខ ក.ស.ច.ស ជំទាស់នឹងការអនុវត្តការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួម នៅ អ.វ.ត.ក[15] ដោយឈរលើមូលដ្ឋានថា៖ ក) វាមិនមានចែងជាក់លាក់ក្នុងច្បាប់បង្កើត អ.វ.ត.ក, ខ) វាមិនមែនជាផ្នែកនៃច្បាប់កម្ពុជា, គ) វាមិនត្រូវបានគេទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយសូម្បីវាស្ថិតនៅសព្វថ្ងៃនេះ វាមិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងរវាងឆ្នាំ ១៩៧៥-៧៩ ឬ មិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអាចអនុវត្តបានដោយផ្ទាល់នៅតុលាការកម្ពុជា និង ឃ) វាមិនត្រូវបានទទួលស្គាល់ដោយអនុសញ្ញាអន្តរជាតិទាំងឡាយដែលអាចអនុវត្តបានដោយផ្ទាល់នៅ អ.វ.ត.ក[16]។ ទឡ្ហីករណ៍ទាំងនេះស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងទឡ្ហីករណ៍ដែល ក.ស.ព នឹងតតាំងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ ក.ស.ព បច្ចុប្បន្ន។

10. ស្ថិតក្នុងកាលៈទេសៈទាំងនេះជាមួយនឹងបញ្ហាអង្គហេតុ និងអង្គច្បាប់ស្ទើរដូចគ្នាបេះដាក់ មេធាវីការពារក្តីសូមស្នើថា អំណះអំណាងពី លោក **អៀង សារី** នឹងត្រូវបានអនុញ្ញាត។ ការណ៍នេះយកទៅតាមវិធីសាស្ត្រដែលប្រកាន់យកដោយតុលាការសេរ៉ាលេអូន នៅក្នុងរឿងក្តី *Kallon* ដែលអង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដោយត្រូវដាក់ក្នុងនាម Moinina Fofana and Augustine Gbao ដោយអន្តរាគមគាំទ្រដល់ការតតាំងនឹងបញ្ហា

---

[14] *ករណី លោក អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិស្នើសុំរបស់លោក អៀង សារី ស្តីអំពី សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១១ សីហា ២០០៨ កថាខណ្ឌ ៤ ។

[15] *ករណី លោក អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ញត្តិស្នើសុំរបស់លោក អៀង សារីប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២៨ កក្កដា ២០០៨ ។

[16] *ដូចគ្នា ខាងលើ នៅទំព័រ ១ ។*

យុត្តាធិការរបស់មេធាវីការពារក្តី ទោះបីជា Fofana បានស្ថិតនៅក្នុងរឿងក្តីទីទៃពីគ្នាក៏ដោយ[17]។ ប្រហែលគ្នានេះដែរ នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលរបស់ ICTY បានប្រឈមមុខនឹងបណ្តឹងឧទ្ធរណ៍ទាក់ទងទិដ្ឋភាពតូចមួយនៃ ការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួម ដែលមានផលប៉ះពាល់ជាសក្តានុពលដល់ជនជាប់ចោទទាំងអស់ប្រឈមមុខនឹង ការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួម *សមាគមមេធាវីការពារក្តីប្រកបវិជ្ជាជីវៈនៅតុលាការ ICTY* (ADC-ICTY) ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលស្នើអោយដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ[18] ហើយក៏ត្រូវបានអនុញ្ញាតអោយធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់[19] ទៅលើបញ្ហានោះ ជាការគាំទ្រដល់សេចក្តីសន្និដ្ឋានទាំងឡាយដែលដាក់ក្រុមមេធាវីការពារក្តីឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍នោះ។

11. ខណៈដែលវាអាចទៅរួចថា មេធាវីការពារក្តីរបស់ **ឌុច** នឹងធ្វើសេចក្តីសន្និដ្ឋានប្រហាក់ប្រហែលគ្នានឹងមេធាវីការពារក្តីរបស់ លោក **អៀង សារី** ស្តីពីការអនុវត្តនូវសហឧក្រិដ្ឋកម្មរួមនេះ សហមេធាវីការពារក្តីរបស់ **ឌុច** មានកាតព្វកិច្ចតែចំពោះកូនក្តីរបស់ខ្លួនតែមួយគត់។ ពួកគេប្រហែលជាមិនត្រូវបានគេរំពឹងទុក ឬមិនតម្រូវ អោយការពារអោយបានពេញលេញចំពោះផលប្រយោជន៍របស់លោក **អៀង សារី** ឡើយ ដូចអ្វីដែលត្រូវបានការពារដោយសហមេធាវីការពារក្តីដែលតំណាងនូវផលប្រយោជន៍របស់ លោក **អៀង សារី** ឡើយ។ ហេតុដូច្នេះ តម្រូវការសម្រាប់មេធាវីការពារក្តី ដើម្បីធ្វើអន្តរាគមន៍ក្នុងនាម លោក **អៀង សារី** ។

## ខ. ភាពស្មុគស្មាញនៃការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួម និង គោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តីគ្នា

---

[17] សូមមើល *រដ្ឋអាជ្ញា តតាំងនឹង Kallon, សំណុំរឿង* SCSL-2004-15-AR72(E), សេចក្តីសំរេចទៅលើការតតាំងនឹងបញ្ហាយុត្តាធិការ៖ កិច្ចព្រមព្រៀងលើកលែងទោសនៅ Lomé ចុះថ្ងៃទី ១៣ មីនា ២០០៤ នៅទំព័រទី ៣ ។

[18] *រដ្ឋអាជ្ញា តតាំងនឹង Brđanin*, សំណុំរឿងលេខ IT-99-36-A, សេចក្តីសំរេចស្តីពីញត្តិស្នើសុំបដិសេធចោលនូវទឡ្ហីករណ៍ទីមួយនៃបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ចុះថ្ងៃទី ៥ ឧសភា ២០០៥ ។

[19] សូមមើល *រដ្ឋអាជ្ញា តតាំងនឹង v. Brđanin, សំណុំរឿង* IT-99-36-A, សេចក្តីសំរេចលើសំណើរបស់សមាគមមេធាវីការពារក្តី ADC សុំចូលរួមក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី ៧ វិច្ឆិកា ២០០៥ ។ *សូមមើលផងដែរ* សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់សមាគមមេធាវីការពារក្តី ADC នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា តតាំងនឹង Brđanin សំណុំរឿង* IT-99-36-A ប្រតិចារឹកនៃនីតិវិធីបណ្តឹងឧទ្ធរណ៍ ទំព័រ ៦៤-៧២ ចុះថ្ងៃទី ៧ ធ្នូ ២០០៦ ។

12. សហឧក្រិដ្ឋកម្មរួម គឺជាទម្រង់មួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលបង្កអោយមានការរិះគន់ជាសាធារណៈ[20]។ មិនមានទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌណាផ្សេងទៀត ដែលបង្កអោយមានការរិះគន់យ៉ាងជ្រាលជ្រៅដោយអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ ក្នុងទំហំប្រហែលគ្នានេះឡើយ[21]។ ការអនុវត្តដោយផ្ទាល់នូវទម្រង់នៃការទទួលខុសត្រូវនេះនៅតុលាការជាតិ ដូច អ.វ.ត.ក

---

[20] "ចាប់តាំងពីសាលដីកានៃរឿងក្តីរបស់ *Tadić* ចុះថ្ងៃទី ១៥ កក្កដា ១៩៩៩ សហឧក្រិដ្ឋកម្មរួម (JCE) ដែលជាទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ បានវិវឌ្ឍទៅជាធាតុផ្សំមួយដែលមានលក្ខណៈប្រទាំងប្រទើសនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិសារធាតុ"។ *មានទោសដោយសារការចងជាបក្សពួក៖សហឧក្រិដ្ឋកម្មរួមនាពេលជំនុំជម្រះ* ដោយ Göran Sluiter 5 J. INT'L CRIM. JUST. 67 (2007)។

[21] សាស្ត្រាចារ្យ Dershowitz បានពិពណ៌នា សហឧក្រិដ្ឋកម្មរួម JCE ថាជា"ការប្រមូលផ្តុំ ព្រមជាមួយនឹងការលាតសន្ធឹងនៃទម្រង់ទាំងប្រាំ អនុញ្ញាតអោយរដ្ឋអាជ្ញា និង ចៅក្រមបូកបញ្ចូលលភស្តុតាងប្រឆាំងលើជនជាប់ចោទដោយខុសច្បាប់ ដើម្បីដាក់បន្ទុកលើជនជាប់ចោទចំពោះឧក្រិដ្ឋកម្មដែលមានលក្ខណៈទូទៅមួយចំនួន ដោយគ្មានភស្តុតាងដែលថា ជនជាប់ចោទធ្វើ "ផែនការ", "បានញុះញង់", "បានបញ្ជា", "បានប្រព្រឹត្ត" ឬ "បានសម្របសម្រួលនិងផ្តល់ជំនួយ" នូវអំពើឧក្រិដ្ឋជាក់លាក់ណាមួយ"។ *រដ្ឋអាជ្ញា តតាំងនឹង Krajišnik* សំណុំរឿងលេខ IT-00-39-A សារណាស្តីអំពី សហឧក្រិដ្ឋកម្មរួម តាងនាមអោយ Momčilo Krajišnik ចុះថ្ងៃទី ៤ មេសា ២០០៨ កថាខណ្ឌ ៤។ ចំពោះការកត់សំគាល់ស្រដៀងគ្នានេះ សូមមើលអត្ថបទរបស់ Mohamed Elewa Badar ក្រោមចំណងជើងថា "ផ្តន្ទាទោសមនុស្សគ្រប់រូប" (Just Convict Everyone!)- ការប្រព្រឹត្តរួមគ្នា៖ ចាប់ពី *Tadić* ទៅដល់ *Stakić* 293 Int'l Crim. L. Rev. 301 (2006)។ "ប្រភពនៃការព្រួយបារម្ភទាក់ទងនឹងការអនុវត្ត CJE-III... គឺថា... អ្នកចូលរួមត្រូវទទួលខុសត្រូវយ៉ាងអយុត្តិធម៌ចំពោះអំពើព្រហ្មទណ្ឌដែលគាត់ពុំមានបំណង ហើយក៏មិនបានចូលរួមដែរ ។ វាក៏អយុត្តិធម៌ដែលថា ការទទួលខុសត្រូវរបស់ចារី (អ្នកដែលប្រព្រឹត្តបទល្មើសដែលនៅខាងក្រៅផែនការរួម) ត្រូវបានវាយតំលៃដោយតាមជំនឿរបស់ខ្លួន(subjectively) រីឯអ្នកចូលរួមវិញ ត្រូវបានវាយតំលៃដោយផ្អែកអង្គហេតុពិត (objectively) ។ សំខាន់ជាងនេះទៅទៀត ប្រសិនបើជនជាប់ចោទពិតជាបានចូលរួមក្នុងបទល្មើសខាងក្រៅ "ផែនការគោលបំណងរួម"ដំបូង ក្នុងឋានៈជាអ្នកសម្របសម្រួលឬអ្នកផ្តល់ជំនួយ ពួកគេនឹងមានឱកាសរួចផុតពីការចោទប្រកាន់ដោយអាចតវ៉ាបាន ខណៈដែលអយ្យការនឹងបញ្ឈមមុខជាមួយការបង្ហាញភស្តុតាងដើម្បីគាំទ្រដល់ស្មារតីយល់ដឹងកម្រិតខ្ពស់ ដែលមានន័យថាជនជាប់ចោទដឹងថាចារីផ្ទាល់នៃបទល្មើសមានធាតុអត្តនោម័តដែលតម្រូវសំរាប់ឧក្រិដ្ឋកម្មដែលចោទប្រកាន់។ ជាចុងក្រោយហើយកាន់តែដុនដាបថែមទៀត សហឧក្រិដ្ឋកម្មរួមជាទម្រង់លាតសន្ធឹង (JCE) III (Extended form) ត្រូវបានប្រើប្រាស់ ដើម្បីផ្តន្ទាទោសអ្នកចូលរួមនៅក្នុងផែនការរួមសម្រាប់បទល្មើសដែលប្រព្រឹត្តដោយចារីពិតប្រាកដ ទោះបីជាអ្នកចូលរួមពុំមានធាតុអន្តោម័តឬចេតនាពិរុទ្ធដែលជាលក្ខខណ្ឌតម្រូវសម្រាប់បទល្មើសដែលចោទប្រកាន់ (ជាពិសេសឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់)" ។ សាស្ត្រាចារ្យ Danner និង Martinez បានរកឃើញថា សហឧក្រិដ្ឋកម្មរួម (JCE) "លើកតម្កើងភាពអស្ចារ្យនៃពិរុទ្ធភាពតាមរយៈការចងក្រងជាបក្សពួក និងផ្តល់ប្រដាប់ចម្បាំងដល់អ្នកដែលមិនជឿទុកចិត្តទៅលើភាពម៉ឺងម៉ាត់ និងភាពឥតលំអៀងនៃវេទិកាអន្តរជាតិ ។ Allison Marston Danner & Jenny S. Martinez, *ពិរុទ្ធភាពដោយសារតែការចងក្រងជាបក្សពួក (Guilty Associations): សហាកម្មឧក្រិដ្ឋកម្មរួម, ការទទួលខុសត្រូវជាមេបញ្ជាការ និង ការវិវឌ្ឍន៍នៃច្បាប់ប្រហ្មទណ្ឌអន្តរជាតិ* (*Joint Criminal Enterprise, Command Responsibility, and the Development of International Criminal*

នេះ តម្រូវអោយមានដំណោះស្រាយនូវបញ្ហាបន្ថែមទៀតនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ព្រហ្មទណ្ឌ និងច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ដែលមិនត្រូវបានថ្លែងប្រាស្រ័យពីមុនដោយតុលាការមួយចំនួនតូចដែលបានអនុវត្តនូវការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួម។ មេធាវីការពារក្តីសូមអះអាងថា អង្គបុរេជំនុំជម្រះ នឹងត្រូវបានផ្តល់ជាជំនួយតាមរយៈសេចក្តីសន្និដ្ឋានពីមេធាវីការពារក្តីទៅលើបញ្ហាដ៏ស្មុគស្មាញនេះ។

13. ការបដិសេធមេធាវីការពារក្តីនូវឱកាសដើម្បីដាក់សេចក្តីសន្និដ្ឋាន នឹងនាំអោយមានការដកហូតពីលោក **អៀង សារី** នូវសមភាពខាងនីតិវិធី ដូច្នេះបង្កើតបានជាការបំពារបំពាននូវគោលការណ៍ *សមភាពនៃមធ្យោបាយតទល់ក្តីគ្នា* [22]។ ដោយច្បាស់លាស់ ក.ស.ព នឹងអាចមានលទ្ធភាពដាក់សេចក្តីសន្និដ្ឋាននៅចំពោះមុខ អង្គបុរេជំនុំជម្រះ អំពីបញ្ហាដែលមានផលប៉ះពាល់ដោយផ្ទាល់លើលោក **អៀង សារី** ប៉ុន្តែ លោក **អៀង សារី** ខ្លួនឯងមិនអាចធ្វើដូច្នេះបាន ។ គ្មានអ្វីដែលមិនអាចថាមិនមានយុត្តិធម៌ជាចម្បងនោះទេ។

## គ. ផលប្រយោជន៍សេដ្ឋកិច្ចនៃតុលាការ

14. ការដោះស្រាយបញ្ហានៅដំណាក់កាលនេះគឺថា តើការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួមដែលអនុវត្តនៅចំពោះមុខ អ.វ.ត.ក អាចនឹងជួយលើកស្ទួយដល់សេដ្ឋកិច្ចរបស់តុលាការ និងនាំឲ្យកិច្ចស៊ើបសួរ និងសវនាការបន្តបន្ទាប់ទៀតប្រព្រឹត្តទៅបានឆាប់រហ័ស ដែរឬយ៉ាងណានោះ ។ គេក៏បានដឹងយ៉ាងច្បាស់ដែរថា អ.វ.ត.ក កំពុងប្រឈមមុខនឹងបញ្ហាខ្វះថវិកាយ៉ាងធ្ងន់ធ្ងរនៅក្នុងការបញ្ចប់បេសកកម្មរបស់ខ្លួន។ នៅក្នុងកាលៈទេសៈបែបនេះ វាជាការចាំបាច់ណាស់ដែលថា ថវិកាដែលឧបត្ថម្ភពីប្រភពសាធារណៈមិនត្រូវចំណាយទៅលើការស៊ើបសួរ និង ការចោទប្រកាន់លើ

---

*Law)*, 93 Cal. L. Rev. 75, 137 (2005) ។ លោក Marston Danner & Jenny S. Martinez បានគត់សំគាល់បន្ថែមទៀតថា "ប្រសិនបើការសមគំនិត គឺជាចំណង់ចំណូលចិត្តរបស់រដ្ឋអាជ្ញាសហរដ្ឋអាមេរិកពិតមែន នោះវាពិបាកនឹងយល់ថាតើសហឧក្រិដ្ឋកម្មរួម (JCE) អាចបង្កើតបានជាអ្វីមួយដែលតិចជាគ្រាប់បែកនុយក្លេអ៊ែររបស់ឃ្លាំងស្តុកអាវុធរបស់រដ្ឋអាជ្ញាអន្តរជាតិ" ។

[22] *រដ្ឋអាជ្ញា តតាំងនឹង Tadić* សំណុំរឿងលេខ IT-94-1-A, សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៥ កក្កដា ១៩៩៩ កថាខណ្ឌ ៤៨ ដល់ ៥២ ។

ទម្រង់នៃការទទួលខុសត្រូវមួយ ដែលតាមពិតទៅប្រហែលជាមិនអាចយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក បាននោះទេ។ ប្រសិនបើការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួម ត្រូវបានរកឃើញថាមិនអាចអនុវត្តនៅចំពោះមុខ អ.វ.ត.ក បានទេ នោះបញ្ហានេះនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើកិច្ចស៊ើបសួររបស់ ក.ស.ច.ស នៅក្នុងរឿងក្ដីរបស់លោក **អៀង សារី, អៀង ធីរិទ្ធ, នួន ជា** និង **ខៀវ សំផន** ខណៈដែលផែនការឧក្រិដ្ឋកម្មរួម គឺជាមូលដ្ឋានសំខាន់បំផុតនៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរដែលបានដាក់ប្ដឹងដោយ ក.ស.ព ។

**ឃ. ជាផលប្រយោជន៍នៃយុត្តិធម៌ និង តម្លាភាព សេចក្ដីសន្និដ្ឋានផ្ទាល់មាត់ ត្រូវបានធានា**

15. មេធាវីការពារសូមស្នើដោយក្ដីគោរពថា បណ្ដឹងឧទ្ធរណ៍នេះនឹងនាំឱ្យមានសវនាការផ្ទាល់មាត់។ ក្នុងការជំទាស់ទៅនឹងសវនាការផ្ទាល់មាត់ ក.ស.ព អះអាងថា៖ ក) "ភាគីនានាអាចដាក់សេចក្ដីសង្ខេបឱ្យបានគ្រប់គ្រាន់ស្ដីពីបញ្ហាអង្គហេតុ និងអង្គ ច្បាប់ពាក់ព័ន្ធ ជូនទៅ អង្គបុរេជំនុំជម្រះ តាមរយៈសេចក្ដីសន្និដ្ឋានជាលាយលក្ខអក្សររបស់ខ្លួន"[23] និង ខ) សេចក្ដីត្រូវការនូវដំណោះស្រាយមួយឱ្យបានឆាប់រហ័ស អំពីបញ្ហាតាមផ្លូវច្បាប់នានាដែលនៅសេសសល់ ដើម្បីអាចចាប់ផ្ដើមបើកការជំនុំជម្រះក្ដីជាសាធារណៈឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន"[24]។ ជាសរុបមក <u>ហេតុផលទាំងអស់នេះមិនគ្រប់គ្រាន់</u> ដើម្បីគេចផុតពីការសន្មតទុកជាមុនឱ្យមានសវនាការដេញដោលផ្ទាល់មាត់ចំពោះបណ្ដឹងឧទ្ធរណ៍ដាក់ជូន អង្គបុរេជំនុំជម្រះ ដូចដែលវិធានផ្ទៃក្នុងបានកំណត់នោះទេ[25]។

---

[23] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៩ ។

[24] ដូចខាងលើ ។

[25] មានសេចក្ដីសន្និដ្ឋានឱ្យមានសវនាការផ្ទាល់មាត់មួយដែលចែងយ៉ាងច្បាស់នៅក្នុងវិធានផ្ទៃក្នុង ៧៧(៤) ដែលសំអាងទៅលើសិទ្ធិរបស់ភាគី "អាចសុំមើលសំណុំរឿងរហូតដល់ថ្ងៃ<u>សវនាការ</u>"។ មាត្រា ៨.៤ នៃសេចក្ដីណែនាំអនុវត្តអំពីការដាក់ឯកសារដែលចែងថា "សំណើឆ្លើយតបចំពោះសារណាតបនឹងត្រូវអនុញ្ញាត នៅក្នុងករណីតែមិនមានការស្នើសុំឱ្យមាន<u>ការដេញដោល</u>ដោយផ្ទាល់ មាត់ទៅលើសំណើនេះ"។ បទប្បញ្ញត្តិនេះសន្និដ្ឋានថា នឹងមានសវនាការផ្ទាល់មាត់ និងកំណត់ពីការឆ្លើយតបជាលាយលក្ខអក្សរ ដែលជាអញ្ញត្រកម្មចំពោះគោលការណ៍នេះ។

16. ដោយសារថា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនឹងផ្តល់ជូន អង្គបុរេជំនុំជម្រះ ពីជំហររបស់គូភាគីទាក់ទងនឹងការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួមនោះ មានតែចៅក្រមអង្គបុរេជំនុំជម្រះទេដែលអាចចោទសួរគូភាគី និងអ្នកចូលរួមទាំងឡាយពាក់ព័ន្ធនៅក្នុងបណ្តឹងឧទ្ធរណ៍ថា បញ្ហាជាមូលដ្ឋាននេះនឹងត្រូវបានដោះស្រាយឲ្យបានគ្រប់ជ្រុងជ្រោយ។ លើសពីនេះទៅទៀត ដំណើរការនេះអាចផ្តល់មធ្យោបាយប្រកបដោយឧត្តមគតិវិសេសវិសាលបំផុត ដែលតាមរយៈនេះ សាធារណៈជនអាចនឹងត្រូវបានជូនដំណឹងយ៉ាងពេញលេញ ។

17. អង្គបុរេជំនុំជម្រះមិនគួរចុះញ៉មទៅតាមភាពភ័យខ្លាចមិនត្រឹមត្រូវលើកឡើងដោយ ក.ស.ព ចំពោះការពន្យាពេលបើក ការជំនុះជម្រះលើរូប **ឌុច** នោះទេ។ សេចក្តីត្រូវការឲ្យមានដំណោះស្រាយមួយឆាប់រហ័សចំពោះបញ្ហាដែលនៅសេសសល់នៅក្នុងរឿងក្តីរបស់ **ឌុច** <u>មិនអាច</u>យកមកធ្វើយុត្តិកម្មការប្រញាប់ប្រញាល់ពេកតាមរយៈបណ្តឹងឧទ្ធរណ៍នេះទេ ជាពិសេស នៅពេលដែលសេចក្តីសម្រេចនោះនឹងធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ភាពយុត្តិធម៌យូរអង្វែងនៃកិច្ចស៊ើបសួរដទៃទៀត និងសវនាការនាពេលបន្តបន្ទាប់។

## IV. សេចក្តីសន្និដ្ឋាន និង ការស្នើសុំរកភាពធូរស្រាល

18. មេធាវីការពារសូមលើកឡើងថា ការអនុវត្តការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួម នៅ អ.វ.ត.ក គឺជាបញ្ហាមួយដ៏ស្មុគស្មាញបំផុតដែលអង្គបុរេជំនុំជម្រះនឹងត្រូវប្រឈមមុខ។ ហើយវាក៏ជាបញ្ហាមួយដែលប៉ះពាល់ដោយផ្ទាល់ និងយ៉ាងធ្ងន់ធ្ងរដល់លោក **អៀង សារី**។ វាជាការមួយគួរឲ្យហួសចិត្តបំផុត ប្រសិនបើមេធាវីការពារមិនត្រូវបានអនុញ្ញាតឲ្យដាក់សេចក្តីសន្និដ្ឋានស្តីពីបញ្ហាដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍របស់ **ឌុច** ខណៈដែលអ្នកទាំងឡាយដែលមានផលប្រយោជន៍ ឬការយល់ដឹងដ៏តិចតួចទៅលើដំណើរការនីតិវិធី ត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងសវនាការទៅលើបណ្តឹងឧទ្ធរណ៍មុនៗនៅចំពោះមុខអង្គបុរេជំនុំជម្រះនោះ។

**អាស្រ័យហេតុនេះ** សម្រាប់ហេតុផលទាំងអស់ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ មេធាវីការពារ សូមសំណូមពរដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះសូម ÷

ក. ផ្តល់សិទ្ធិឲ្យមេធាវីការពារដាក់ជូនសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនេះ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ទៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាដំណោះស្រាយលើករណីរបស់ ឌុច នៅក្នុងរយៈពេល ១៥ថ្ងៃគិតពីថ្ងៃចេញសេចក្តីសម្រេចមក។

ខ. បង្គាប់ថា ត្រូវមានសវនាការផ្ទាល់មួយស្តីពីបញ្ហាអង្គច្បាប់ចំពោះបណ្តឹងឧទ្ធរណ៍នេះ និងអនុញ្ញាតឲ្យមេធាវីការពារដាក់ជូនសេចក្តីសន្និដ្ឋានផ្ទាល់មាត់នៅក្នុងសវនាការនោះ។

សូមអង្គបុរេជំនុំជម្រះទទួលយកសំណើសុំនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៨

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**